

# សេចក្តីថ្លែងការណ៍
# របស់អង្គការមិនមែនរដ្ឋាភិបាលទៅកាន់
# វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា
# ឆ្នាំ២០០៨

ភ្នំពេញ
វិច្ឆិកា ២០០៨

# មាតិកា


១. សេចក្តីផ្តើម ........ ១

២. បញ្ហាអាទិភាព ........ ២

២.១ ដីធ្លី កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ ........ ២

២.២ អភិបាលកិច្ចល្អ ........ ៦

២.៣ ការអភិវឌ្ឍធនធានមនុស្ស ........ ១១

៣. ផែនការអនាគត ........ ១៣


## ១. សេចក្តីផ្តើម

ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជា គ្របដណ្តប់ទៅលើបញ្ហាអភិវឌ្ឍន៍យ៉ាងទូលំទូលាយ និងបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយជីវិត និងស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជា។ មូលដ្ឋានរួមរបស់អង្គការទាំងអស់គឺក្នុងគោលបំណងដើម្បីលើកកម្ពស់តួនាទីរបស់ជនក្រីក្រ និងក្រុមងាយរងគ្រោះ នៅក្នុងសង្គមកម្ពុជា។ តាមរយៈការរួមបញ្ចូលគ្នានូវព័ត៌មាន និងចំណេះដឹងពីថ្នាក់មូលដ្ឋានអង្គការសង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់ក្នុងការជួយរាជរដ្ឋាភិបាលកម្ពុជា រៀបចំធ្វើគោលនយោបាយដោយធ្វើការចែករំលែក និងផ្តល់ព័ត៌មានត្រលប់និងសំណូមពរទាំងឡាយ ទាក់ទងនឹងគោលនយោបាយអភិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយ ។

សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលទៅកាន់វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ឆ្នាំ ២០០៨ បានកំណត់យកបញ្ហាអាទិភាពចំនួនបីគឺ : ១- ដីធ្លី កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ ២- ការអភិវឌ្ឍធនធានមនុស្ស និង ៣-អភិបាលកិច្ចល្អ។ ក្នុងនោះការអភិវឌ្ឍគោលនយោបាយសមស្រប និងរាល់កម្មវិធីកំណែទម្រង់មានសក្តានុពលខ្លាំងក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាក្រីក្រ និងងាយរងគ្រោះរាប់លាននាក់។ ភាគច្រើននៃគោលនយោបាយ និងកម្មវិធីកំណែទម្រង់ទាំងនេះសុទ្ធសឹងតែមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-១០។

បន្ថែមលើសេចក្តីថ្លែងការណ៍នេះ អង្គការមិនមែនរដ្ឋាភិបាលបានរៀបចំឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលដែលរួមមានចំនួន ២៥វិស័យ ស្តីអំពីការអភិវឌ្ឍរបស់កម្ពុជាក្នុងឆ្នាំ២០០៧-០៨ ក្នុងគោលបំណងផ្តល់ព័ត៌មានត្រឡប់ក្នុងន័យស្ថាបនា លើវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករតាមដានរួមគ្នាក្នុងឆ្នាំ២០០៧-០៨។ ឯកសារដែលបានបោះពុម្ពផ្សាយនេះមានឈ្មោះថា **"ឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលស្តីអំពីការអភិវឌ្ឍរបស់កម្ពុជាក្នុងឆ្នាំ២០០៧-០៨"** ដែលជាឯកសារគោលនៃសេចក្តីថ្លែងការណ៍ របស់អង្គការមិនមែនរដ្ឋាភិបាលនេះ។ ឯកសារនេះត្រូវបានផ្សេរៀបចំដាក់បញ្ជូនដាច់ពីគ្នា ទៅវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ កម្ពុជា។

## ២. បញ្ហាអាទិភាព

- ***ផ្នែកដីធ្លី កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ*** ឆ្លុះបញ្ចាំងអំពីកង្វល់របស់អង្គការមិនមែនរដ្ឋាភិបាល ទាក់ទងទៅនឹងគំរូនៃការអភិវឌ្ឍដែលមិនមានសមធម៌ក្នុងវិស័យកសិកម្ម ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ ដែលការអភិវឌ្ឍនេះផ្តល់ផលប្រយោជន៍ឱ្យប្រជាជនភាគតិចប៉ុណ្ណោះ ប៉ុន្តែបង្កឱ្យមានផលប៉ះពាល់ធំធេង ទៅដល់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និងអ្នកងាយរងគ្រោះបំផុត។
- ***ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស*** បង្ហាញពីបញ្ហាគន្លឹះ និងអនុសាសន៍ ដែលមានសារសំខាន់ក្នុងការលើកកម្ពស់វិស័យអប់រំ និងវិស័យសុខាភិបាល។
- ***ផ្នែកអភិបាលកិច្ចល្អ*** រៀបរាប់ពីការព្រួយបារម្ភរបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីអំពីសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ សេរីភាពសារព័ត៌មាន កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

### ២.១ ដីធ្លី កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ

អភិក្រមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ហាក់បីដូចជាផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការជួលដីធ្លី ការប្រើប្រាស់ធនធានធម្មជាតិ និងកំណើនសេដ្ឋកិច្ចក្នុងកម្រិតមួយ ខណៈដែលប្រជាជនក្រីក្រ និងងាយរងគ្រោះបំផុតមិនសូវទទួលបានផលប្រយោជន៍សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ។ បញ្ហានេះអាចបង្កឱ្យមានផលប៉ះពាល់ចំពោះគោលដៅយុទ្ធសាស្រ្តចតុកោណ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងបង្កឱ្យមានឧបសគ្គធំៗចំពោះអភិបាលកិច្ចល្អ គណនេយ្យភាព និងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។

**អតិផរណា និងការឡើងថ្លៃម្ហូបអាហារ** នៅក្នុងប្រទេសកម្ពុជា បង្កើតឱ្យមានកាលានុវត្តភាពផង និងការគម្រាមកំហែងផង។ ដោយសារប្រទេសកម្ពុជាជាប្រទេសនាំចេញកសិផល ការឡើងថ្លៃនៃតម្លៃម្ហូបអាហារអាចផ្តល់នូវឱកាសមាសមួយសម្រាប់លើកកំពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទ (ប្រជាជនកម្ពុជាក្រីក្រ ៩១ភាគរយរស់នៅទីជនបទដែលពឹង អាស្រ័យលើ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) តាមរយៈការពង្រីកវិស័យកសិកម្ម និងសន្តិសុខស្បៀង។ ទោះបីជាយ៉ាងនេះក៏ដោយក៏កម្ពុជានៅមានបញ្ហាប្រឈម។ កសិករមិនសូវមានលទ្ធភាពទិញសម្ភារៈកសិកម្ម(សម្រាប់ប្រើក្នុងមួយវដ្តផលិតកម្ម)ក្នុងតម្លៃខ្ពស់ និងមិនសូវទទួលបាននូវជំនួយបច្ចេកទេស និងព័ត៌មានទីផ្សារដែលនេះជាឧបសគ្គដ៏ធ្ងន់ធ្ងរមួយចំពោះពិពិធភាវូបនីយកម្មកសិកម្មការបង្កើនផលិតភាព និងការបង្កើតទីផ្សារសម្រាប់ផលិតផលគ្រួសារ។ វិស័យកសិកម្មរបស់ប្រទេសកម្ពុជាពឹងអាស្រ័យច្រើន លើទឹកភ្លៀងសម្រាប់ការផលិត និងងាយរងគ្រោះពីគ្រោះមហន្តរាយ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត និងការបំផ្លាញពីពពួកសត្វល្អិត។ កង្វះខាតនូវប្រភពទឹកសម្រាប់កសិដ្ឋានខ្នាតតូច និងមធ្យម នៅតែជាឧបសគ្គដ៏ធំមួយដោយសារកង្វះការវិនិយោគទុនក្នុងប្រព័ន្ធធារាសាស្ត្រ និងកង្វះខាតការកសាងសមត្ថភាពរបស់អ្នកប្រើប្រាស់ក្នុងការថែទាំប្រព័ន្ធធារាសាស្ត្រ។ ការកើនឡើងនៃតម្លៃសម្ភារៈកសិម្ម (សម្រាប់ប្រើក្នុងមួយវដ្តផលិតកម្ម) ជាពិសេសការកើនឡើងតម្លៃជីគីមីគឺជាឧបសគ្គជាចម្បងមួយផងដែរ។ ទីផ្សារ និងតម្លៃផលិតផលកសិកម្មនៅតែមិនមានលំនឹងដោយសារការពឹងអាស្រ័យលើពាណិជ្ជករបរទេស និងកង្វះការកែច្នៃ និង ការវេចខ្ចប់។

ទោះបីយ៉ាងនេះក្តី ថ្លៃដើមលិតកម្មខ្ពស់បានផ្តល់នូវការលើកទឹកចិត្តឱ្យមានការប្រើប្រាស់វិធីសាស្ត្រដែលប្រើបច្ចេកវិទ្យាទាបដូចជាកសិកម្មសរីរាង្គ និងប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ដែលបានទទួលស្គាល់ថាជាវិធីសាស្ត្រដែលចំណាយថ្លៃដើមទាប ទទួលផលបានផលចំណេញខ្ពស់ និងមានប្រសិទ្ធភាពខ្ពស់ក្នុងការថែរក្សាជីវជាតិដីកសិកម្ម និងចីរភាពបរិស្ថាន។ លើសពីនេះ តម្រូវឱ្យមានក្រុមសហគមន៍ជួយខ្លួនឯងបន្ថែមទៀត ដូចជា សមាគម និងសហករណ៍កសិករ ក្រុមសន្សំប្រាក់ ធនាគារស្រូវ និងក្រុមអ្នកប្រើប្រាស់ទឹកជាដើម។ ក្រុមទាំងនេះត្រូវការជំនួយបន្ថែមទៀតដើម្បីផ្តល់លទ្ធភាពឱ្យពួកគេអាចធ្វើការរួមគ្នា ជាពិសេសលើផ្នែកទីផ្សារ និងឥណទាន។

ការបែងចែកដីធ្លីប្រកបដោយសមធម៌ និងកម្មសិទ្ធិដីធ្លីដែលមានសុវត្ថិភាព គឺជាបុព្វលក្ខខណ្ឌសម្រាប់ផលិតភាពកសិកម្មប្រកបដោយប្រសិទ្ធភាព។ ខណៈដែលប្រទេសកម្ពុជាគឺជាប្រទេសនាំស្រូវចេញ គ្រួសារកសិករត្រឹមតែ ៣៥ភាគរយប៉ុណ្ណោះដែលផលិតបរិមាណស្រូវលើស។ ភាគច្រើនពួកគាត់ត្រូវទិញម្ហូបអាហារបន្ថែមសម្រាប់ការបរិភោគ។ ហេតុដូចនេះ **ការឡើងថ្លៃម្ហូបអាហារមានផលប៉ះពាល់អវិជ្ជមានចំពោះអ្នកទិញអាហារសុទ្ធ** ដូចជាកម្មករដែលមានប្រាក់ខែថេរ អ្នកគ្មានដីធ្លី និងមានដីធ្លីតិចតួច (គ្រួសារជនបទ ៤៦ភាគរយ គ្មានដីធ្លី និងមានដីតិចតួច)។ ជាពិសេស គេសង្កេតឃើញថា **សហគមន៍នេសាទ** ទទួលរងផលប៉ះពាល់ខ្លាំងបំផុតពីការឡើងថ្លៃម្ហូបអាហារ ដោយសារផលនេសាទមានការធ្លាក់ចុះ រីឯតម្លៃត្រីឡើងថ្លៃតិចតួចបំផុតបើធៀបទៅនឹងថ្លៃម្ហូបអាហារដទៃទៀត។ ដូចនេះ គ្រួសារក្រីក្រនៅទូទាំងប្រទេសកម្ពុជាត្រូវបង្ខំចិត្តដោះស្រាយនឹងបញ្ហានេះដោយការកាត់បន្ថយបរិមាណអាហារប្រចាំថ្ងៃ ការបរិភោគអាហារមិនសូវមានជីវជាតិ កាត់បន្ថយចំណាយលើការសិក្សា និងសុខភាព ធ្វើចំណាកស្រុក លក់ទ្រព្យសម្បត្តិ ឬខ្ចីបំណុល។ ដំណោះស្រាយទាំងនេះបានជម្រុញឱ្យប្រជាជនក្រីក្រធ្លាក់កាន់តែជ្រៅក្នុងអន្ទាក់នៃភាពក្រីក្រ។

ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមានទាំងនេះ និងដើម្បីទាញយកផលប្រយោជន៍ពីកាលានុវត្តភាពនៃការឡើងថ្លៃម្ហូបអាហារនេះ ទាមទារឱ្យមានការចង្អុលបង្ហាញ ឬការណែនាំពីគោលនយោបាយសាធារណៈ និងការធ្វើអន្តរាគមន៍ពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់។ អាទិភាពត្រូវផ្តោតលើការពង្រីកកម្មវិធីការពារផ្នែកសង្គមកិច្ច ការពន្លឿនការផ្តល់កម្មសិទ្ធិដីធ្លីនៅតំបន់ជនបទ និងការដោះស្រាយជម្លោះដីធ្លី ការបែងចែកដីធ្លីដល់គ្រួសារគ្មានដីនិងគ្រួសារដីតិចតួចតាមរយៈដីសម្បទានសង្គមកិច្ច ការធ្វើពិពិធភាវូបនីយកម្មដំណាំ និងការបង្កើនការវិនិយោគក្នុងការសិក្សាស្រាវជ្រាវនិងការផ្សព្វផ្សាយពង្រីកវិស័យកសិកម្ម បច្ចេកទេសផលិតប្រកបដោយចីរភាព ការកែច្នៃផលិតផល និងការស្វែងរកទីផ្សារ វិស័យអភិវឌ្ឍន៍ជនបទ (ផ្លូវជនបទ និង ប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងខ្នាតមធ្យមដែលកសិករអាចគ្រប់គ្រងបាន) និង ការគ្រប់គ្រងធនធានទឹក។

ទោះបីការផ្តល់កម្មសិទ្ធិដីធ្លីជាលក្ខណៈប្រព័ន្ធកំពុងដំណើរការទៅមុខជាលំដាប់ក្តី មានភស្តុតាងកាន់តែច្រើនដែលបញ្ជាក់ថាកម្មវិធីកំណែទម្រង់ដីធ្លីមិនអាចសម្រេចគោលបំណងរបស់ខ្លួនបានឡើយ។ មានចំណែកសំខាន់ៗជាច្រើននៃ **ការគ្រប់គ្រង ការបែងចែក និងរដ្ឋបាលដីធ្លី** មិនមានដំណើរការប្រកបដោយប្រសិទ្ធភាពទេ ដូចជាការកំណត់អត្តសញ្ញាណ និងការកំណត់ព្រំដែនដីរដ្ឋ ការខ្វះចន្លោះក្នុងការផ្តល់កម្មសិទ្ធិដីធ្លីនៅទីក្រុង ការចុះបញ្ជីកម្មសិទ្ធិដីធ្លីជាបន្តបន្ទាប់ បញ្ជីកម្មសិទ្ធិដីធ្លីមិនទាន់ចែកចាយ ករណីជម្លោះមិនទាន់ដោះស្រាយមុនគណៈកម្មការសុរិយោដី តួនាទីមិនច្បាស់លាស់របស់អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី ការមិនទទួលស្គាល់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និងការចូលរួមមានកម្រិតរបស់សង្គមស៊ីវិលក្នុងដំណើរការរៀបចំគោលនយោបាយ។ លើសពីនេះទៀត ភាពមិនច្បាស់លាស់នៃគោលនយោបាយ និងកម្រិតយល់ដឹងទាបរបស់មន្ត្រី

មូលដ្ឋានកំពុងបង្កឱ្យមានការរើសអើងចំពោះស្ត្រីដែលបានធ្វើការលែងលះជាមួយប្តី ស្ត្រីដែលរស់នៅបែកពីប្តី និងស្ត្រីដែលប្តីបោះបង់ចោល នៅតាមតំបន់មួយចំនួនដែលពួកគេមិនត្រូវបានផ្តល់ឱកាសស្មើគ្នាក្នុងការចុះបញ្ជីកម្មសិទ្ធិទោលដោយប្រើឈ្មោះរបស់ពួកគេផ្ទាល់នោះទេ។ **ជនជាតិដើមភាគតិច** នៅតែបន្តទទួលរងការបាត់បង់កម្មសិទ្ធិកាន់កាប់ដីធ្លី និងធនធានធម្មជាតិ។ ពួកគេត្រូវទទួលរងគ្រោះដោយការកើនឡើងនៃដីសម្បទានសេដ្ឋកិច្ច និងសម្បទានរុករករ៉ែ នៅតំបន់ភាគខាងជើង និងភាគឥសាន។ រហូតមកដល់ពេលនេះពុំទាន់មានសហគមន៍ជនជាតិដើមភាគតិចណាមួយបានទទួលកម្មសិទ្ធិដីសមូហភាពនៅឡើយទេ ហើយការខ្វះចន្លោះក្នុងការអនុវត្តវិធានការការពារជាបឋមរបស់រាជរដ្ឋាភិបាល បានឆ្លុះបញ្ចាំងពីកង្វះឆន្ទៈនយោបាយសម្រាប់ការពារដីកសិកម្មតាមបែបប្រពៃណីរបស់ពួកគេ។ រាជរដ្ឋាភិបាល ត្រូវផ្តល់អាទិភាពដល់ការធានា**សុវត្ថិភាពកម្មសិទ្ធិដីធ្លីរបស់គ្រួសារក្រីក្រនៅទីប្រជុំជន** តាមរយៈវិធានការដ៏មឺុងម៉ាត់ដែលធានាថា ចំនួនកម្មសិទ្ធិត្រូវបានផ្តល់ឱ្យម្ចាស់កម្មសិទ្ធិនៅទីប្រជុំជនទាំងឡាយណាដែលបានបំពេញគ្រប់លក្ខខណ្ឌទាមទាររបស់ផ្លូវច្បាប់ និងជម្រុញការចុះបញ្ជីឱ្យបានឆាប់រហ័សព្រមទាំងធ្វើការដាក់កម្រិតលើការចំណាយទាំងឡាយណាដែលពាក់ព័ន្ធនឹងការចេញប័ណ្ណកម្មសិទ្ធិម្តងៗ។ គណៈកម្មការសុរិយោដីគ្រប់លំដាប់ថ្នាក់ត្រូវមានធនធានគ្រប់គ្រាន់សម្រាប់ដោះស្រាយករណីដីធ្លីតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធិភាពនៅតាមខេត្ត/ក្រុង និងបញ្ជាក់ឱ្យច្បាស់អំពីយុត្តាធិការរបស់អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លីដែលស្របទៅនឹងនីតិរដ្ឋ។ នីតិវិធីត្រូវបង្កើតដើម្បីធានាឱ្យមាន**ការបញ្ច្រាបយេនឌ័រ**ប្រកបដោយប្រសិទ្ធភាពនៅក្នុងគោលនយោបាយកំណែទម្រង់ដីធ្លី និងការអនុវត្តគោលនយោបាយនេះ ដើម្បីធានាការការពារ និងការលើកកម្ពស់សិទ្ធិមេគ្រួសារជាស្ត្រី។

ចំការកសិឧស្សាហកម្មខ្នាតធំក្នុងប្រទេសកម្ពុជាបានបង្ហាញឱ្យឃើញថាមានផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅរបស់ប្រជាជន និងពុំសូវមានប្រសិទ្ធភាពដូចកសិដ្ឋានខ្នាតតូចទេបើគិតពីផលិតផលក្នុងមួយហិកតា។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តផ្តល់ចំណែកដីដ៏ធំធេងរបស់ប្រទេសកម្ពុជាឱ្យទៅអ្នកវិនិយោគទុនក្នុងរូបភាព **ដីសម្បទានសេដ្ឋកិច្ច ការរុករករ៉ែ និងសម្បទានទេសចរណ៍**។ ដីសម្បទានសេដ្ឋកិច្ចនេះមានលក្ខណៈគួរឱ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងកង្វះវឌ្ឍនភាពនៃការបែងចែកដីធ្លីទៅឱ្យកសិករគ្មានដី តាមរយៈដីសម្បទានសង្គមកិច្ច និងការបែងចែកព្រៃឈើទៅឱ្យក្រុមសហគមន៍ព្រៃឈើ ។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចជាច្រើន ពុំបានអនុវត្តតាមនិតិវិធីច្បាប់ដែលការពារសហគមន៍រងគ្រោះ និងបរិស្ថានទេ ដែលជាហេតុធ្វើឱ្យកើតមានការរំលោភសិទ្ធិមនុស្សជាច្រើនករណី។

ចំណែកមួយភាគបីនៃ**តំបន់អភិរក្សជីវចម្រុះ**នៅក្នុងខេត្តមណ្ឌលគីរី និងរតនគីរីត្រូវបានគេធ្វើការបែងចែក ឬ បានស្នើធ្វើការបែងចែកសម្រាប់ ការរុករករ៉ែ ការផ្តល់ដីសម្បទានសេដ្ឋកិច និងការកសាងទំនប់វារីអគ្គីសនី។ ដីសម្បទានជាច្រើនក្នុងប្រទេសកម្ពុជាមិនទាន់បានប្រើប្រាស់សម្រាប់ការងារផលិតកម្មនៅឡើយ ហើយហាក់ដូចជាប្រើប្រាស់ក្នុងគោលបំណងចំណេញពីការឡើងថ្លៃ ឬជាយន្តការមួយសម្រាប់កាប់ឈើ ខុសច្បាប់ប៉ុណ្ណោះ។

ការផ្តល់ និងការប្រើប្រាស់អាជ្ញាប័ណ្ណសម្បទាន និងរុករករ៉ែគួរត្រូវបានផ្អាកជាបណ្តោះអាសន្នសិនរហូតដល់ដីរដ្ឋត្រូវបានកំណត់ព្រំដែន និងការចុះបញ្ជីរួច និងការកំណត់តំបន់អភិរក្ស និងតំបន់ព្រៃឈើត្រូវបានអនុត័ត និងការផ្តល់កម្មសិទ្ធិដីសមូហភាពរបស់ជនជាតិដើមភាគតិចត្រូវបានអនុម័តចប់សព្វគ្រប់។ ស្របពេលគ្នានេះដែរគម្រោងដីសម្បទានសង្គមកិច្ចគួរត្រូវពង្រីកទូទាំង ប្រទេសដើម្បីធានាថាការផ្តល់ដិសម្បទាននេះទទួលបានអាទិភាពប្រហាក់ប្រហែលគ្នានឹងការផ្តល់ដីសម្បទានសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ត្រូវរៀបចំធ្វើគោលនយោបាយជាតិសម្រាប់ការទទួលខុសត្រូវផ្នែកសង្គម

និងបរិស្ថាន  ក្នុងវិស័យឧស្សាហកម្មនិស្សារណកម្មដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយក្រសួងតែមួយគត់។  ក្របខ័ណ្ឌព្រៃឈើសហគមន៍ (ក្នុងន័យទូលាយបំផុត) ត្រូវបង្កើតការអនុម័តដែលទទួលស្គាល់សហគមន៍ព្រៃឈើដែលនៅសេសសល់ កំណត់អត្តសញ្ញាណ  សហគមន៍ព្រៃឈើសម្រាប់ភូមិដែលនៅសេសសល់ទាំងអស់ព្រមទាំទទួលស្គាល់សិទ្ធិរបស់សហគមន៍ក្នុងការចូលរួមក្នុងការគ្រប់គ្រងព្រៃឈើអាជីវកម្មរបស់សហគមន៍ប្រកបដោយចីរភាពនិងផលិតភាពដោយផ្អែកលើសិទ្ធិរបស់ពួកគេនៅក្នុងច្បាប់ព្រៃឈើ។ ដូចគ្នានេះដែររាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ចាំបាច់ត្រូវសម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាពជាងមុនដើម្បីគាំទ្រសហ គមន៍នេសាទ។

រាជរដ្ឋាភិបាលកំពុងរៀបចំផែនការ  និងសាងសង់**ទំនប់វារីអគ្គិសនី**ទូទាំងប្រទេសកម្ពុជាដើម្បីបំពេញតម្រូវការថាមពលដែល ចេះតែកើនឡើង។ នៅតំបន់ឆ្នេរសមុទ្រ និងភាគនិរតីនៃប្រទេសកម្ពុជា គម្រោងវារីអគ្គិសនីប្រាំ កំពុងត្រូវបានអនុវត្តខណៈដែលយ៉ាងតិចគម្រោង ១៣ទៀតកំពុងស្ថិតក្នុងការពិចារណាធ្វើការសាងសង់ទូទាំងប្រទេស។ ដោយសារការរៀបចំគម្រោងមិនមានតម្លាភាព សង្គមស៊ីវិលព្រួយបារម្ភថាការរៀបចំផែនការ និងការសាងសង់ទំនប់វារីអគ្គិសនីទាំងនេះនឹងធ្វើឡើងដោយមិនមានការពិនិត្យគ្រប់គ្រាន់ និងទប់ស្កាត់ផលប៉ះពាល់ដល់បរិស្ថានសង្គម និងសេដ្ឋកិច្ចដែលនឹងធ្វើឱ្យការចំណាយរបស់គម្រោងទាំងនេះមានតម្លៃច្រើនលើសពីអត្ថប្រយោជន៍ដែលនឹងទទួលបាន។ ប្រសិនបើគ្មានតម្លាភាពគណនេយ្យភាព និងការចូលរួមរបស់សាធារណជនក្នុងការរៀបចំផែនការថាមពលរបស់ប្រទេសកម្ពុជាទេនោះប្រជាជនក្រីក្រ និងក្រុមប្រជាជនងាយរងគ្រោះ ដែលពឹងអាស្រ័យលើធនធានធម្មជាតិសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ នឹងនៅតែបន្តខាតបង់ដោយសារកំណើនសេដ្ឋកិច្ច។ ដើម្បីជៀសវាងការចំណាយច្រើនលើការសាងសង់ទំនប់វារីអគ្គិសនី រាជរដ្ឋាភិបាលកម្ពុជាត្រូវរៀបចំ**យុទ្ធសាស្ត្រ ថាមពលថ្នាក់ជាតិ** ដោយ មានការចូលរួមពីភាគីពាក់ព័ន្ធចម្រុះ ប្រកបដោយតម្លាភាព សមធម៌ និងចីរភាព។ នៅពេលអនុវត្តន៍ យុទ្ធសាស្ត្រថាមពលគួរគោរពតាមច្បាប់ជាតិនិងបទដ្ឋាននៃការអនុវត្តអន្តរជាតិដូចមានបញ្ជាក់ដោយគណៈកម្មការពិភពលោកស្តីពីទំនប់វារីអគ្គិសនី ។

អង្គការមិនមែនរដ្ឋាភិបាលព្រួយបារម្ភថាជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះបំផុតនឹងបន្តរងការគម្រាមកំហែងលុះត្រាណាបញ្ហាជាមូលដ្ឋាននៃកង្វះការសម្របសម្រួល ឬ**ការរៀបចំផែនការអភិវឌ្ឍប្រកបដោយសុខុដុមភាវូបនីយកម្ម ក្នុងវិស័យដីធ្លី និងធនធានធម្មជាតិ** ត្រូវបានកែសម្អ។ ការផ្សព្វផ្សាយព័ត៌មានមិនបានគ្រប់គ្រាន់និងកង្វះការយល់ដឹងអំពីផលប៉ះពាល់រួមក៏គឺជាការព្រួយបារម្ភជាក់លាក់មួយផងដែរ។ ម្យ៉ាងវិញទៀតអង្គការមិនមែនរដ្ឋាភិ-បាលព្រួយបារម្ភអំពីកង្វះកាលានុវត្តភាពសម្រាប់ការពិគ្រោះយោបល់ភាគីពាក់ព័ន្ធ ឱ្យទូលំទូលាយក្នុងពេលកំពុងធ្វើគោលន-យោបាយ ដូចជា ក្រុមប្រតិបត្តិកម្ពុជាសម្រាប់ការងារជលផល និងកម្មវិធីព្រៃឈើជាតិ។ ដើម្បីអភិវឌ្ឍប្រទេសកម្ពុជាដោយមានការគិតគូអំពី តម្រូវការរបស់ប្រជាពលរដ្ឋគំរូនៃការអភិវឌ្ឍ ត្រូវធានាឱ្យមានការបែងចែកផលប្រយោជន៍និងការចំណាយប្រកបដោយសមធម៌។ ដូចដែលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិលើកឡើងបញ្ហានេះអាស្រ័យលើការពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ការបង្កើនវិមជ្ឈការនៃការគ្រប់គ្រងធនធានតាមរយៈគំរូអភិវឌ្ឍន៍សហគមន៍ និងការធានាថាអ្នកវិនិយោគពាណិជ្ជកម្មធ្វើការពិគ្រោះយោបល់ និងឆ្លើយតបទៅនឹងប្រជាពលរដ្ឋមូលដ្ឋានដែលរងផលប៉ះពាល់ដោយសារប្រតិ-បត្តិការទាំងនេះឱ្យបានគ្រប់គ្រាន់។ ដូចនេះអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យទាំងនេះសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ គាំទ្រ និងចូលរួមជាមួយសំណើសុំទាំងអស់ ដើម្បីចងក្រងក្រុមការងារបច្ចេកទេសជាក្រុម

ការងារសម្រាប់សម្រួលដល់សុខុដុមនីយកម្មនៃអភិក្រម និងការអន្តរាគមន៍នានាក្នុងវិស័យដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ។

ការរកឃើញធនធានប្រេង ឧស្ម័ន និងរ៉ែ បានលើកបញ្ហាថាតើត្រូវអភិវឌ្ឍវិស័យ **ឧស្សាហកម្មនិស្សារណកម្ម** នៅប្រទេសកម្ពុជាបែបណាឱ្យល្អបំផុត ជាពិសេសទាក់ទងទៅនឹងការគ្រប់គ្រងនៅថ្ងៃអនាគតលើប្រាក់ចំណូលដែលទំនងជានឹងទទួលបាន។ ជាក្តីសង្ឃឹមគឺថាប្រទេសកម្ពុជានឹងមានឯករាជ្យភាពពីជំនួយអភិវឌ្ឍន៍ ហើយសេដ្ឋកិច្ចរបស់ប្រទេសនឹងរីកចំរើនដែលនឹងជួយជម្រុញឱ្យមានកំណើនសេដកិច្ចខ្ពស់សម្រាប់ការអិវឌ្ឍប្រកបដោយចិរភាព។ ក៏ប៉ុន្តែដោយមានប្រទេសមួយចំនួនឆ្លងកាត់ពិសោធន៍នៃការទទួលបានចំណូលយ៉ាងសន្ធឹកសន្ធាប់ពីធនធាន នោះទាមទារឱ្យមានការរៀបចំផែនការដោយប្រុងប្រយ័ត្នដើម្បីធានាថាកំណើននៃប្រាក់ចំណូលនិងចំណាយភ្លាមៗនោះ មិនមានផលប៉ះពាល់អាក្រក់ទៅលើបរិយាកាសម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងស្ថេរភាពនយោបាយ។ ដោយសារតម្លាភាពបង្កឱ្យរដ្ឋាភិបាលមានសក្តានុពលនិងជម្រើសប្រសើរក្នុងការចរចាជាមួយវិនិយោគទុនបរទេស អង្គការមិនមែនរដ្ឋាភិបាលសូមផ្តល់ជាអនុសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាគួរអនុម័តចូលជាសមាជិកការផ្តួចផ្តើមគំនិតស្តីពីតម្លាភាពនៃឧស្សាហកម្មនិស្សារណកម្មក្នុងឆ្នាំ២០០៩ នេះ។ អង្គការមិនមែនរដ្ឋាភិបាលស្នើរសូមឱ្យរាជរដ្ឋាភិបាលបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះតម្លាភាពនៃប្រាក់ចំណូលពីឧស្សាហកម្មនិស្សារណកម្មឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន ក្នុងនោះរួមបញ្ចូលទាំងបង្ហាញប្រាក់ចំណូលពីឧស្សាហកម្មនិស្សារណកម្មនៅក្នុងការបោះពុម្ពផ្សាយប្រចាំខែពីប្រាក់ចំណូលនិងចំណាយរបស់ខ្លួន បោះពុម្ពផ្សាយបញ្ជីឈ្មោះទាំងក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ័ និងក្រុមហ៊ុនដែលរងចាំទទួលអាជ្ញាបណ្ណ័ ព្រមទាំងកិច្ចសន្យានាពេលបច្ចុប្បន្ននិងអនាគត ភ្ជាប់ការពិគ្រោះយោបល់ពិតប្រាកដជាមួយសាធារណៈជន និងសង្គមស៊ីវិល ស្តីពីសេចក្តីព្រាងច្បាប់ប្រេងកាត និងច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើឧស្សាហកម្មធនធានធម្មជាតិ ព្រមទាំងរួមបញ្ចូលធនធានរ៉ែ ទៅក្នុងការសិក្សានៅថ្ងៃអនាគតស្តីអំពីការគ្រប់គ្រងធនធានឧស្សាហកម្មនិស្សារណកម្ម។

## ២.២ អភិបាលកិច្ចល្អ

អង្គការសង្គមស៊ីវិលក្នុងស្រុក និងអន្តរជាតិ មានការព្រួយបារម្ភជាខ្លាំង អំពីគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានប្រកាសថា នឹងអនុម័ត**ច្បាប់សមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**។ ខណៈដែលប្រទេសកម្ពុជាកំពុងធ្វើដំណើរលើផ្លូវទៅកាន់កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ យើងមានការព្រួយបារម្ភយ៉ាងខ្លាំងថា រាជរដ្ឋាភិបាលកម្ពុជា នឹងប្រើច្បាប់អង្គការនេះ ដើម្បីបន្ថយតួនាទីឯករាជ្យរបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការគាំទ្រសហគមន៍ទាំងអស់ ដែលកន្លងមកឫយ៉ាងណាដោយអង្គការទាំងនេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងកំណើន និងការអភិវឌ្ឍប្រទេសប្រកបដោយចិរភាពនិងសមធម៌។

ទោះបីអង្គការមិនមែនរដ្ឋាភិបាលជាសហគមន៍មិនមែនរដ្ឋាភិបាលក៏ពិតមែន ប៉ុន្តែអង្គការទាំងនេះមិនមែនស្ថិតនៅក្រោមវង្វង់ក្របខ័ណ្ឌច្បាប់របស់ប្រទេសឡើយ។ អង្គការមិនមែនរដ្ឋាភិបាលគោរពច្បាប់ប្រទេស និងគោលនយោបាយជាតិ។ ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាលត្រូវការក្របខ័ណ្ឌគោលនយោបាយអនុវត្តន៍ដ៏ល្អ ដើម្បីចូលរួមលើកកម្ពស់សុខុដុមភាវូបនីយកម្ម និង សង្គតភាពរបស់គម្រោងផ្តល់ជំនួយថ្មីដែលមានផលប៉ះពាល់ដល់កំណើន និងការអភិវឌ្ឍសង្គមជាតិ។

ដូចនេះ ច្បាប់អង្គការអាចមិនមានភាពចាំបាច់ទេនៅពេលបច្ចុប្បន្ននេះ។ ប៉ុន្តែ ប្រសិនបើមានច្បាប់នេះ នាពេលអនាគត យើងសូមអំពាវនាវសុំឱ្យមានការពិគ្រោះយោបល់អំពីច្បាប់នេះជាមួយអង្គការមិនមែនរដ្ឋាភិបាលឱ្យបានទូលំទូលាយមុនពេលដាក់ជូនរដ្ឋសភាជាតិធ្វើការអនុម័ត។ ទង្វើនេះគឺដើម្បីធានាថាអង្គការមិនមែនរដ្ឋាភិបាល នឹងបន្តធ្វើជាកាត្តាលីករ និងជាតួអង្គឯករាជ្យ ដែលដើរតួនាទីយ៉ាងសកម្ម និងមានផលប្រយោជន៍ សម្រាប់ការផ្លាស់ប្តូរ និងការអភិវឌ្ឍសង្គមជាតិ។

អង្គការមិនមែនរដ្ឋាភិបាលសង្កេតឃើញថារដ្ឋាភិបាលមិនសូវមានវិធានការដោះស្រាយអំពើពុករលួយឡើយបើធៀបទៅនឹងឆ្នាំមុន។ ក្នុងពេលទន្ទឹមគ្នានេះដែរ អង្គការមិនមែនរដ្ឋាភិបាលកាន់តែមានការព្រួយបារម្ភអំពីការមិនមានកាលបរិច្ឆេទកំណត់សម្រាប់ការបញ្ចប់ និងអនុម័តតារាងសូចនាករតាមដានរួមនៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០០៧ ចំពោះ **ច្បាប់ប្រឆាំងអំពើពុករលួយ**។ រយៈពេលមួយឆ្នាំបានកន្លងផុតទៅបន្ទាប់ពីកិច្ចប្រជុំនៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកចុងក្រោយ នៅមិនទាន់មានវឌ្ឍនភាពជាក់ស្តែងក្នុងដំណើរការនីតិកម្មនៅឡើយ ប៉ុន្តែរាជរដ្ឋាភិបាលបានធ្វើសេចក្តីថ្លែងការណ៍ជាច្រើនក្នុងពេលថ្មីៗ ដោយបានប្រកាសថាសេចក្តីព្រាងក្រមព្រហ្មទណ្ឌដែលផ្សាភ្ជាប់ជាចាំបាច់ជាមួយសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយបានត្រៀមពិនិត្យឡើងវិញ និងអនុម័តដោយរដ្ឋសភាជាតិហើយច្បាប់ប្រឆាំងអំពើពុករលួយនឹងត្រូវបានអនុម័តជាបន្ទាប់។ ទោះបីមានមន្ទិលសង្ស័យចំពោះសេចក្តីថ្លែងការណ៍នេះក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាលសូមសម្តែងនូវការអបអរសាទរ និងសូមលើកទឹកចិត្តរាជរដ្ឋាភិបាល និងរដ្ឋសភាជាតិឱ្យបន្តដំណើរការជាមួយក្រមព្រហ្មទណ្ឌនេះដូចដែលបានធ្វើជាមួយក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីជម្រុញឱ្យច្បាប់ប្រឆាំងអំពើពុករលួយឱ្យអនុម័តក្នុងពេលឆាប់ៗ ដូចច្បាប់ដែលបានអនុម័តកន្លងមក។

ក្នុងពេលទន្ទឹមគ្នានេះ អង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ថាសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយថ្មីនេះមានការកែលម្អខ្លះៗបើប្រៀបធៀបទៅនឹងសេចក្តីព្រាងច្បាប់ឆ្នាំ២០០៣។ ទោះបីជាយ៉ាងនេះក្តី ច្បាប់នេះនៅមានកម្រិតទាបជាងបទដ្ឋានអន្តរជាតិ ដូចដែលបានព្រមព្រាងរវាងរាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយនៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ក្នុងឆ្នាំ២០០៤។

ដូចនេះ អង្គការមិនមែនរដ្ឋាភិបាលសូមសំណូមពរឱ្យមានការពិនិត្យឡើងវិញ និងកែលម្អពង្រាងច្បាប់នេះ ឱ្យត្រូវតាមបទដ្ឋានអន្តរជាតិ ដោយគិតពិចារណាអំពីនុសាសន៍ និងយោបល់របស់សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល លើបញ្ហាសំខាន់ៗដូចខាងក្រោម :

- និយមន័យរបស់អំពើពុករលួយនៅក្នុងសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ (សេចក្តីព្រាងច្បាប់ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៦) នឹងត្រូវពិនិត្យឡើងវិញ ដើម្បីឱ្យច្បាប់នេះមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលគ្របដណ្តប់រាល់ទិដ្ឋភាពនៃអំពើពុករលួយ។
- សម្រាប់ឯករាជភាពនៃការប្រតិបត្តិការងាររបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ប្រឆាំងអំពើពុករលួយ គួរមាននាទីត្រឹមតែទីប្រឹក្សាហើយអគ្គលេខាធិការត្រូវតែឯករាជ្យទាំងស្រុងក្នុងប្រតិបត្តិការប្រចាំថ្ងៃ ជាពិសេសក្នុងមុខងារស៊ើបអង្កេតរបស់ខ្លួន។ ថវិកាស្វយ័តរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវតែចែងឱ្យបានច្បាស់ថាការបើកថវិកានឹងត្រូវធ្វើឡើងនៅខែទីមួយនៃឆ្នាំ។

- ការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រី ត្រូវតែរាប់បញ្ចូលទាំងទ្រព្យសម្បត្តិរបស់ភរិយា និងកូនក្នុងបន្ទុកផងដែរ។ អគ្គលេខាធិការ របស់ស្ថាប័នប្រឆាំងអំពើពុករលួយ នឹងត្រូវបានអនុញ្ញាតឱ្យពិនិត្យទ្រព្យសម្បត្តិដែលបានប្រកាសនៅពេលណាមួយ ដែលចាត់ទុកថាចាំបាច់ក្នុងដំណើរការស៊ើបអង្កេត។
- ការរក្សាការសម្ងាត់ មិនគ្រប់គ្រាន់ដើម្បីធានាឱ្យមានការចូលរួមរបស់សាធារណជន ដែលមានសារៈសំខាន់បំផុតសម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងប្រទេសណាមួយប្រកបដោយជោគជ័យនោះ។ មាត្រា ៨០ នៃសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយថ្មីនេះ មិនគ្រាន់តែមិនបានផ្តល់នូវការការពារដល់សាក្សីទេ ប៉ុន្តែមាត្រានេះបែរជាដាក់បន្ទុកព្រហ្មទណ្ឌទៅលើពួកគេទៅវិញ។ ដូចនេះ អង្គការមិនមែនរដ្ឋាភិបាលចង់ឱ្យមានការពិនិត្យ និងកែសម្រួល មាត្រានេះឡើងវិញ ដើម្បីធានាថាសាក្សីទទួលបាននូវការការពារ។
- នៅក្នុងបរិបទប្រទេសកម្ពុជាបច្ចុប្បន្ន វាមិនយុត្តិធម៌ទេក្នុងការកាត់ទោសអ្នកផ្តល់សំណូកដែលមិនមានចេតនា ប៉ុន្តែត្រូវបានទាមទារដោយមន្ត្រីសាធារណៈហើយពួកគេគ្មានជម្រើស។ ប៉ុន្តែ ពិតជាមានមនុស្សដែលមានចេតនាផ្តល់នូវសំណូកដល់មន្ត្រីដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន និងមិនស្របច្បាប់។ ដូចច្នេះ មានតែអ្នកមានចេតនាផ្តល់សំណូកទាំងនោះទេ ដែលគួរត្រូវបានកាត់ទោសតាមច្បាប់។

ការព្រួយបារម្ភមួយទៀតគឺការបង្កើត**ក្របខ័ណ្ឌគោលនយោបាយស្តីពីលទ្ធភាពទទួលព័ត៌មាន**។ ក្រសួងទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា និងអធិការកិច្ច បានចាត់វិធានការជាក់ស្តែងតិចតួចក្នុងកំឡុងពេលកំពុងពិនិត្យឡើងវិញ ហើយមានការប្តេជ្ញាចិត្តបន្តិចបន្តួចដើម្បីធ្វើឱ្យដំណើរការនេះឆ្ពោះទៅមុខ។ អង្គការមិនមែនរដ្ឋាភិបាលសូមទទូចឱ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ចប់ក្របខ័ណ្ឌគោលនយោបាយស្តីពីលទ្ធភាពទទួលព័ត៌មានក្នុងកំឡុងឆ្នាំថ្មីនេះ។

សហគមន៍អង្គការមិនមែនរដ្ឋាភិបាល ទទួលស្គាល់ការបង្កើត និងការផ្សព្វផ្សាយជាសាធារណៈនូវយុទ្ធសាស្ត្រ**កំណែទម្រង់ប្រព័ន្ធច្បាប់និងតុលាការ** ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្សព្វផ្សាយនៅក្នុងឆ្នាំ២០០៣ ព្រមទាំងមានបំណងជាថ្មីម្តងទៀត ឱ្យមានការប្រើប្រាស់អត្ថប្រយោជន៍របស់យុទ្ធសាស្ត្រកំណែទម្រង់នេះនៅក្នុងការអនុវត្តកំណែទម្រង់ក្នុងវិស័យឱ្យមានប្រសិទ្ធភាព។ ដោយសារការគោរពនីតិរដ្ឋមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយសមធម៌ និងចីរភាពក្នុងប្រទេសកម្ពុជា សហគមន៍អង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភាជាតិធ្វើកំណែទម្រង់និងពង្រឹងស្ថាប័នដែលមានតួនាទីលើកកម្ពស់នីតិរដ្ឋនិងការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ព្រមទាំងជម្រុញឱ្យមានការគោរពច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ។

ឧទាហរណ៍ គួរធ្វើកំណែទម្រង់ស្ថាប័នសំខាន់ៗដែលមានស្រាប់ផ្សេងៗ រួមទាំងគណៈកម្មាធិការរៀបចំការបោះឆ្នោត ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញ។ នៅទីបំផុត យើងខ្ញុំសូមបញ្ជាក់ជាថ្មីថាក្រុមប្រឹក្សាឧត្តមអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញដែលបានបង្កើតឡើងក្រោមច្បាប់រដ្ឋធម្មនុញ្ញដើម្បីធានាឱ្យមានឯករាជភាពរបស់តុលាការ និងភាពស្របគ្នារបស់ច្បាប់ផ្សេងៗដែលស្របតាមរដ្ឋធម្មនុញ្ញ ត្រូវការពង្រឹងបន្ថែមដើម្បីការពារទប់ទល់នឹងការជ្រៀតជ្រែកពីផ្នែកនីតិប្រតិបត្តិណាមួយ។ ដូចនេះ ជាមូលដ្ឋាន ស្ថាប័នទាំងបីនេះចាំបាច់ត្រូវមានលក្ខណៈឯករាជ្យ និងមិនប្រកាន់បក្សពួក។ នេះមានន័យថា ស្ថាប័នទាំងនេះគួរតែឯករាជ្យ មិនប្រកាន់បក្សពួក មានសមត្ថភាព និងគុណសម្បត្តិគ្រប់គ្រាន់ដែលអាចឱ្យជឿទុកចិត្តបាន។

មានច្បាប់ជាច្រើន ដែលបានប្រើប្រាស់ក្នុងតុលាការកម្ពុជានាពេលបច្ចុប្បន្ន ដែលច្បាប់ទាំងនេះត្រូវបានអនុម័តមុនពេលកម្ពុជាបានចូលរួមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា និងមុនពេលការអនុម័តច្បាប់រដ្ឋធម្មនុញ្ញបច្ចុប្បន្ន។ ជាលទ្ធផលច្បាប់ទាំងនេះភាគច្រើនមិនស្របគ្នាជាមួយកាតព្វកិច្ចសន្ធិសញ្ញា និងគោលការណ៍ច្បាប់អន្តរជាតិដែលបានទទួលស្គាល់ក្នុងប្រទេសកម្ពុជាឡើយ។ ដូចនេះ រាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវដោះស្រាយបញ្ហាមិនស្របគ្នាទាំងនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងត្រូវធ្វើច្បាប់ថ្មីដើម្បីធានាថាប្រព័ន្ធច្បាប់អាចមានសមត្ថភាពដោះស្រាយបញ្ហាសំខាន់ៗ ដែលកំពុងកើតមានឡើង។ គំនិតនេះត្រូវបានព្រមព្រៀងគ្នានៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ ក្នុងឆ្នាំ២០០៤ ដែលបានសម្រេចថាទីស្តីការគណៈរដ្ឋមន្ត្រីនឹងអនុម័តច្បាប់សំខាន់ជាមូលដ្ឋានទាំងប្រាំបី ហើយដាក់ជូនទៅរដ្ឋសភាជាតិនៅដំណាច់ឆ្នាំ២០០៥។ នីតិពន្ធ (ស្ថាប័ននីតិបញ្ញត្តិ) រាជរដ្ឋាភិបាល និងសង្គមស៊ីវិល ត្រូវពិនិត្យឡើងវិញ និងពិភាក្សាច្បាប់ទាំងនេះ ដើម្បីធានាថាខ្លឹមសារច្បាប់ទាំងនេះស្របគ្នាទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ បទដ្ឋានអន្តរជាតិ និងសន្ធិសញ្ញាសិទ្ធិមនុស្សដែលប្រទេសកម្ពុជាបានប្រកាន់យក និងដើម្បីពង្រឹងនីតិរដ្ឋ និងដំណើរការលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។ ឆ្លៀតក្នុងឱកាសនេះ អង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលថ្មី ពន្លឿនផែនការអនុម័តសេចក្តីព្រាងច្បាប់សំខាន់ៗដែលនៅសេសសល់ទាំងអស់ និងបង្កើតតុលាការជំនាញ ដូចជាតុលាការពាណិជ្ជកម្ម តុលាការរដ្ឋបាល តុលាការការងារ និងអង្គជំនុំជម្រះអនីតិជនជាដើម។

ដូចនេះ អង្គការមិនមែនរដ្ឋាភិបាលសូមស្នើឱ្យក្រសួងយុត្តិធម៌ និងភាគីពាក់ព័ន្ធទាំងអស់ធ្វើឱ្យមានវឌ្ឍនភាពក្នុងការបញ្ចប់ និងការអនុម័តច្បាប់គោលសំខាន់ៗ ដូចដែលបានកត់សម្គាល់នៅក្នុងសេចក្តីថ្លែងការណ៍នេះ ហើយច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការ និងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម គួរត្រូវបានអនុម័តជាអាទិភាព។ ម្យ៉ាងវិញទៀត ដើម្បីធានាឯករាជភាពរបស់តុលាការ អង្គការមិនមែនរដ្ឋាភិបាលយល់ឃើញថាច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមគួរមានខមួយដែលចែងថា "ចៅក្រម មិនអាចជាសមាជិករបស់គណបក្សនយោបាយណាមួយ ឬមានការជាប់ទាក់ទងផ្នែកនយោបាយណាមួយឡើយ"។

ដោយសារពិការភាពជាបញ្ហាអន្តរវិស័យ អង្គការមិនមែនរដ្ឋាភិបាលស្នើសុំឱ្យរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើបញ្ហានេះ តាមរយៈការពន្លឿនការអនុម័តសេចក្តីព្រាងច្បាប់ស្តីពី **ការការពារ និងការលើកកម្ពស់សិទ្ធិជនពិការ**។ ដោយសារ ច្បាប់ពិការភាពជាតិ និងអន្តរជាតិ នឹងត្រូវអនុម័តក្នុងពេលឆាប់ៗខាងមុខ ហើយច្បាប់នេះនឹងក្លាយជាផ្នែកមួយនៃប្រព័ន្ធច្បាប់កម្ពុជា រាជរដ្ឋាភិបាលកម្ពុជាត្រូវបានលើកទឹកចិត្តឱ្យធ្វើការពិនិត្យឡើងវិញនូវសង្គតភាពរបស់អនុសញ្ញាស្តីពីសិទ្ធិជនពិការ ជាមួយនឹងច្បាប់ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិជនពិការ និងច្បាប់ជាតិដទៃទៀត ដែលលុបបំបាត់ចោលនូវរាល់រូបភាពនៃការរើសអើង និងសម្រួលដល់ការផ្សព្វផ្សាយព័ត៌មានទៅដល់ជនពិការឱ្យបានដឹងអំពីសិទ្ធិរបស់ពួកគេដោយ អនុលោមទៅតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងច្បាប់ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិជនពិការ។ ដោយសាររាជរដ្ឋាភិបាលបានចុះហត្ថលេខាលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែម ក្នុងឆ្នាំ២០០៧ អង្គការមិនមែនរដ្ឋាភិបាល សូមស្នើឱ្យរាជរដ្ឋាភិបាលបន្តផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែមនៅក្នុងរយៈពេលពីរឆ្នាំទៀត។ លើសពីនេះទៀត នៅក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ រាជរដ្ឋាភិបាល និងរដ្ឋសភាគួរតែពន្លឿនការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការការពារនិងការលើកកម្ពស់សិទ្ធិជនពិការ និងសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌

អនីតិជន។ គួរមានការយកចិត្តទុកដាក់លើការរៀបចំផែនការច្បាស់លាស់មួយ សម្រាប់បង្កើតតុលាការជំនាញពាក់ព័ន្ធនឹងការរៀបរាប់ខាងលើ។

ការប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ នៅក្នុងខែឧសភា ឆ្នាំ ២០០៨ បានឆ្លុះបញ្ចាំងឱ្យឃើញគោលដៅនៃវឌ្ឍនភាពដ៏សំខាន់មួយក្នុង **កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** របស់ប្រទេសកម្ពុជា។ ច្បាប់អង្គការនេះ ផ្តល់និយមន័យបន្ថែមលើក្របខ័ណ្ឌច្បាប់សម្រាប់អភិបាលកិច្ចថ្នាក់ក្រោមជាតិ និងការបំពេញបន្ថែមលើ "ច្បាប់រដ្ឋបាលនិងការគ្រប់គ្រងឃុំ/សង្កាត់ដែលមានស្រាប់" (ឆ្នាំ២០០១) ដោយកំណត់អាណត្តិផ្នែកច្បាប់របស់រចនាសម្ព័ន្ធគ្រប់គ្រង នៅថ្នាក់ខេត្ត និងស្រុក។ ច្បាប់និងបទបញ្ញត្តិសម្ព័ន្ធជាច្រើន ត្រូវតែរៀបចំនិងអនុម័តមុនការបោះឆ្នោតក្រុមប្រឹក្សាខេត្ត ស្រុក ក្នុងពាក់កណ្តាលឆ្នាំ២០០៩។ កិច្ចរៀបចំនេះកំពុងដំណើរការនៅក្នុងអង្គភាពគោលនយោបាយបង្កើតថ្មី ដែលចំណុះឱ្យ "គណកម្មាធិការជាតិដឹកនាំការងារគ្រប់គ្រងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ"។ អង្គការមិនមែនរដ្ឋាភិបាល សង្ឃឹមថាដំណើរការនេះនឹងក្លាយជាដំណើរការពិគ្រោះយោបល់មួយ ហើយនិងមានការបែងចែកអំណាចច្បាស់លាស់រវាង ក្រុមប្រឹក្សា និងក្រុមប្រឹក្សាអភិបាល ព្រមទាំងនីតិវិធីធ្វើការដែលគួសបញ្ជាក់គណនេយ្យភាពរបស់ក្រុមប្រឹក្សាអភិបាល ចំពោះក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

ខណៈដែលការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិដែលជាការបោះជំហានទៅមុខដ៏សំខាន់មួយក្នុងការពង្រឹងអភិបាលកិច្ចថ្នាក់ក្រោមជាតិ ការប្រគល់មុខងារ អំណាច និងធនធានទៅឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិគឺជាល័ក្ខខ័ណ្ឌចាំបាច់ដែលត្រូវធ្វើ ហើយនឹងត្រូវផ្ទេរការវិភាគវិនិច្ឆ័យ និងការសម្រេចចិត្តផ្នែកនយោបាយសំខាន់ៗទៅឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនេះក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។ ការអនុម័តច្បាប់អង្គការ ជាចំណុចចាប់ផ្តើមមួយសម្រាប់ដំណើរការពិនិត្យឡើងវិញនូវមុខងារអភិបាលកិច្ចនិងមុខងារផ្តល់សេវាកម្មតាមវិស័យ និងការបែងចែកអំណាចរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ដូចនេះដំណើរការរៀបចំកម្មវិធីជាតិ និងការអនុវត្តកម្មវិធីជាតិ ចាំបាច់ត្រូវតែមានតម្លាភាពនិងមានការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងករណីដែលត្រូវសម្រេចមតិជាឯកច្ឆ័នតាមអ្វីដែលចង់បាន។

នៅក្នុងរយៈពេលបីឆ្នាំដំបូងនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មិនមានវឌ្ឍនភាពទាក់ទងនឹងការធ្វើសមកាលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីវិនិយោគសាធារណៈ ថវិកាជាតិប្រចាំឆ្នាំ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទេ។ **ការបែងចែកថវិកាជាតិ** ប្រចាំឆ្នាំមិនទាន់បានតម្រឹមទៅតាមអាទិភាពក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនៅឡើយទេ ហើយច្បាប់ថវិកាជាតិប្រចាំឆ្នាំ ក៏មិនបានផ្តល់នូវការប៉ានប្រមាណឱ្យបានត្រឹមត្រូវចំពោះការចំណាយជាក់ស្តែងរបស់សាមីក្រសួងនីមួយៗ។ ម្យ៉ាងវិញទៀត ការចូលរួមរបស់សង្គមស៊ីវិល និងសាធារណជនក្នុងដំណើរការបែងចែកថវិកានៅមានកម្រិតនៅឡើយ ដោយសារមូលហេតុមួយចំណែកដែលបណ្តាលមកពីកង្វះខាតព័ត៌មានជាសាធារណៈអំពីចំនួនថវិកានោះ។ ដូចនេះ ការផ្លាស់ប្តូរដែលអង្គការមិនមែនរដ្ឋាភិបាលចង់ឃើញក្នុងឆ្នាំ២០០៩នោះ គឺថារាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍ នឹងដឹកនាំការតម្រឹមច្បាប់ថវិកាឆ្នាំ២០០៩ ឱ្យត្រូវតាមចំណុចអាទិភាពក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងត្រូវធានាថាការវិនិយោគសាធារណៈ និងការចំណាយជាក់ស្តែងក្នុងវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទត្រូវតែបង្កើនឱ្យបានកាន់តែច្រើន ដើម្បីជាប្រយោជន៍សម្រាប់កសិករខ្នាតតូច។ លើសពីនេះទៀត ដើម្បីលើកកម្ពស់កម្រិតតម្លាភាព និងគណនេយ្យភាព និង ដើម្បីជម្រុញការចូលរួមពីសង្គមស៊ីវិល និងសាធារណជនក្នុង

ដំណើរការនៃការបែងចែកថវិកា អង្គការមិនមែនរដ្ឋាភិបាល សូមស្នើឱ្យរាជរដ្ឋាភិបាលផ្តល់ព័ត៌មានជាសាធារណៈឱ្យបានទាន់ពេលដូចតទៅ : ១) ក្រសួងផ្សព្វផ្សាយនូវតារាងលម្អិតប្រចាំខែ ស្តីពីប្រតិបត្តិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២) ក្រសួងសាម៉ីបន្ថែមព័ត៌មានអំពីការចំណាយមូលធនទៅក្នុងតារាងលម្អិតប្រចាំខែ ស្តីពីប្រតិបត្តិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៣) ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានដឹងអំពីរបាយការណ៍របស់អាជ្ញាធរសវនកម្ម ជាតិ ស្តីពីការអនុវត្តច្បាប់ថវិកាឆ្នាំ២០០៧។

## ២.៣ ការអភិវឌ្ឍធនធានមនុស្ស

ផ្អែកលើការងារ និងបទពិសោធន៍ក្នុងការផ្តល់សេវាអប់រំដល់កុមារកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលយល់ឃើញថាបញ្ហាខាងក្រោមនេះជាបញ្ហាអាទិភាពសម្រាប់**វិស័យអប់រំ**នៅប្រទេសកម្ពុជា។

១. ការលើកទឹកចិត្តគ្រូបង្រៀន

២. ការបង្កើនអត្រាពិតនៃការចូលរៀន និងអត្រាគង់វង្ស សម្រាប់កុមារទាំងអស់

៣. ការលើកកម្ពស់ការអប់រំសម្រាប់កុមារពិការ

ដើម្បីធានាថាកុមារ និងយុវជនកម្ពុជាគ្រប់រូបមានឱកាសស្មើៗគ្នាក្នុងការទទួលបាននូវការអប់រំប្រកបដោយគុណភាព នោះទាមទារឱ្យមានការលើកកម្ពស់កម្រិតវប្បធម៌ និងជំនាញវិជ្ជាជីវៈរបស់គ្រូបង្រៀន ដោយយកចិត្តទុកដាក់ពិសេសទៅលើការផ្តល់ និងការបើកប្រាក់បៀវត្សរ៍សមរម្យ និងទាន់ពេលសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ យោងតាមការសិក្សាស្រាវជ្រាវអំពីគុណតម្លៃគ្រូបង្រៀន[9] បានបង្ហាញឱ្យឃើញថា ប្រាក់បៀវត្សរ៍ទាបគឺជាកត្តាធ្វើឱ្យបាក់ទឹកចិត្តធំជាងគេបំផុតសម្រាប់គ្រូបង្រៀន។ វិធានការដោះស្រាយបញ្ហានេះមានសារសំខាន់ចំពោះការកាត់បន្ថយចំណាយក្រៅផ្លូវការនៅតាមសាលារៀន។

អង្គការមិនមែនរដ្ឋាភិបាលមានការព្រួយបារម្ភថាគោលដៅអប់រំសម្រាប់ទាំងអស់គ្នា និង ចំណុចដៅរៀនចប់ថ្នាក់ទី៩ ១០០ភាគរយក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជានឹងមិនអាចសម្រេចជោគជ័យនៅក្នុងឆ្នាំ២០១០បានទេ។ គោលដៅនិងចំណុចដៅទាំងនេះនឹងមិនអាចសម្រេចបានទេ ប្រសិនបើគ្មានការផ្តោតចំណុចអាទិភាពច្បាស់លាស់ទៅលើកុមារពិការក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអប់រំ និងការបង្កើនអត្រាពិតនៃការចូលរៀននិងអត្រាគង់វង្ស។ ក្នុងឆ្នាំសិក្សា ២០០៦-០៧ សិស្សដែលបានចូលរៀនថ្នាក់ទី១ ត្រឹមតែ ៥២.៥០ ភាគរយប៉ុណ្ណោះបានរៀនដល់ ថ្នាក់ទី៦នៃកម្រិតបឋមសិក្សា។

នៅពេលកុមារមិនបានចូលរៀន ឬ បោះបង់ការសិក្សា មុនពេលបញ្ចប់ការអប់រំមូលដ្ឋាន ឱកាសអនាគតរបស់ពួកគេមានកម្រិតណាស់។ កុមារដែលមិនបានចូលរៀន ឬឆាប់បោះបង់ការសិក្សា ភាគច្រើនចេញពីក្រុមប្រជាជនដែលមានស្ថានភាពលំបាកដូចជា កុមារពិការ អ្នកដែលរស់នៅតំបន់ដាច់ស្រយាល និងអ្នកក្រីក្របំផុត។ កុមារទាំងនេះ មានបន្ទុកកាន់តែធ្ងន់ធ្ងរនៅពេលគ្រូបង្រៀនទារប្រាក់ក្រៅផ្លូវការ ដោយសារគ្រូបង្រៀនមានប្រាក់បៀវត្សរ៍ទាប និង/ឬ ដោយសារពួកគាត់បើកប្រាក់បៀវត្សរ៍ពេញ ឬពាក់កណ្តាល មិនទៀងទាត់។

ជាដំណោះស្រាយលើបញ្ហាទាំងនេះទាមទារឱ្យមានការចាត់វិធានការជាបន្ទាន់ក្នុងការជ្រើសរើសគ្រូបង្រៀន ការបណ្តុះបណ្តាល និងការផ្តល់ប្រាក់បៀវត្សរ៍សមរម្យ និងបង្កលក្ខណៈងាយស្រួលក្នុងការចូលទៅសាលារៀន។ ការផ្តល់នូវការ

---

[9] ភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល ខែវិច្ឆិកា ឆ្នាំ២០០៨

អប់រំប្រកបដោយគុណភាពទាមទារឱ្យមានគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ជាធនធានជំនួយ និងមានកម្លាំងចិត្ត នៅគ្រប់ខេត្ត/ក្រុង ជាពិសេសតំបន់ជនបទ និងដាច់ស្រយាល។

ដើម្បីលើកកម្ពស់ការអប់រំសម្រាប់កុមារពិការនៅតាមសាលារៀន សកម្មភាពចាំបាច់ដែលត្រូវធ្វើគឺការផ្សព្វផ្សាយ និងសំខាន់បំផុតគឺការអនុវត្តគោលនយោបាយអប់រំសម្រាប់កុមារពិការដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ទាំងអស់ក្នុងវិស័យអប់រំ។ គួរមានការឯកភាពគ្នាលើសូចនាករជាក់លាក់ និងចំណុចដៅសម្រាប់ឆ្នាំសិក្សា ២០០៩-១០ ដើម្បីវាស់វែងវឌ្ឍនភាពរបស់កុមារពិការក្នុងៈ ក) ការលើកកម្ពស់ការចូលរៀន ខ) កែលម្អការបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីបំពេញតាមតម្រូវការរបស់កុមារពិការក្នុងវិស័យអប់រំ និង គ) ការបង្កើនគុណភាពអប់រំសម្រាប់កុមារពិការ។

អង្គការមិនមែនរដ្ឋាភិបាលសូមអបអរសាទរយ៉ាងក្លៀវក្លាចំពោះសមិទ្ធិផលដ៏ធំធេងរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជាក្នុង **វិស័យសុខាភិបាល** ក្នុងការកាត់បន្ថយអត្រាមរណៈទារក និងកុមារ ការធ្លាក់ចុះនៃអត្រាប្រេ៉វ៉ាឡង់ជម្ងឺឆ្លង ដូចជា មេរោគអេដស៍/ជំងឺអេដស៍ ជំងឺរបេង និងគ្រុនចាញ់ ការចាក់ថ្នាំវ៉ាក់សាំងដល់ប្រជាពលរដ្ឋបានទូលំទូលាយ និងសមិទ្ធិផលជាច្រើនទៀត។ ទោះជាមានវឌ្ឍនភាពដូចដែលបានអធិប្បាយខាងលើនេះក៏ដោយ សូចនាករសុខភាពរបស់ប្រទេសកម្ពុជានៅមិនទាន់ជឿនលឿនដូចបណ្តាប្រទេសជាច្រើនផ្សេងទៀតនៅក្នុងតំបន់ទេ។ នេះរួមមាន ផលធៀបអត្រាមរណៈមាតាមិនមានការធ្លាក់ចុះ (៤៧២ ក្នុងចំណោម ១០០ ០០០ កើតរស់) អត្រាមរណៈកុមារនិងទារកនៅខ្ពស់នៅឡើយ ជម្ងឺរ៉ាំរ៉ៃកំពុងកើនឡើង (អត្រាប្រេ៉វ៉ាឡង់ជម្ងឺទឹកនោមផ្អែម ៥ ភាគរយ នៅជនបទ និង ១០ភាគរយនៅទីក្រុង អត្រាប្រេ៉វ៉ាឡង់ជម្ងឺលើសឈាម ១២ ភាគរយនៅជនបទ និង ២៥ភាគរយនៅទីក្រុង[២] ។ ការប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិកយ៉ាងអនាធិបតេយ្យ និងឱសថមិនមានវេជ្ជបញ្ជានៅក្នុងវិស័យឯកជន ការសម្រាលកូនមិនមានសុវត្ថិភាព និងការរំលូតកូននៅតាមផ្ទះ និងនៅក្នុងវិស័យឯកជនក្រៅប្រព័ន្ធ វិស័យឯកជនដែលមិនមានការត្រួតពិនិត្យ ការចំណាយថវិកាផ្ទាល់ខ្លួនទៅលើសេវាសុខភាពមានកម្រិតខ្ពស់ ប្រព័ន្ធសាធារណៈមិនមានថវិកាគ្រប់គ្រាន់ ។ល។ ទាំងនេះសុទ្ធតែជាក្តីកង្វល់សំខាន់ៗក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ សហសវត្សរ៍ ទី៤ ទី៥ និងទី៦ ។

បញ្ហាប្រឈមនៅសេសសល់ផ្សេងទៀត ដែលមានសារៈសំខាន់ក្នុងការលើកកម្ពស់សេវាថែទាំសុខភាពក្នុងប្រទេសកម្ពុជារួមមានៈ កង្វះបុគ្គលិកសុខាភិបាលមានជំនាញ ជាពិសេសសម្រាប់ការថែទាំសុខភាពបឋម ដោយសារបញ្ហាប្រាក់បៀវត្សរ៍ និងប្រាក់លើកទឹកចិត្តទាប សេវាថែទាំសុខភាពមានមិនសូវមានគុណភាពល្អ ដោយសារកង្វះឱសថចាំបាច់ និងគ្រឿងបរិក្ខារវេជ្ជសាស្ត្រ។ សមត្ថភាពជំនាញនៅមានកម្រិត និងអាកប្បកិរិយារបស់បុគ្គលិកសុខាភិបាលមិនសមរម្យ ដូចជាពួកគេមិនសូវមានសីលធម៌វិជ្ជាជីវៈ មិនរាក់ទាក់ និងមិនសូវខ្វល់ខ្វាយជាមួយអ្នកជម្ងឺ។ ការបើកថវិកាជាតិរបស់វិស័យសុខាភិបាលមិនទាន់ពេលវេលា និងមិនពេញលេញ។ បញ្ហាប្រាក់បៀវត្សរ៍ទាបបានជម្រុញឱ្យមានការបង់ថ្លៃក្រៅផ្លូវការនៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព និងការធ្វើការងាររដ្ឋផងនិងឯកជនផង ដែលអ្នកផ្តល់សេវាសុខភាពសាធារណៈ ស្ទើរទាំងអស់សុទ្ធតែបំរើការងារផ្តល់សេវាសុខភាពឯកជនទៅឱ្យសាធារណជន។

ទាំងរាជរដ្ឋាភិបាលកម្ពុជា និងទាំងដៃគូអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល សុទ្ធតែបានទទួលស្គាល់តួនាទីដ៏សំខាន់របស់អង្គការសង្គមស៊ីវិល និងការចូលរួមរបស់សហគមន៍ក្នុងការពង្រឹងប្រសិទ្ធភាពនៃការចំណាយធនធានសាធារណៈដែលនាំឱ្យ

[២] របាយការណ៍ក្រសួងសុខាភិបាល និង អង្គការសុខភាពពិភពលោក

មានអភិបាលកិច្ចល្អ និងផលប៉ះពាល់វិជ្ជមានធំធេងលើការលើកកម្ពស់សុខភាពប្រជាជន។ ទោះបីជាយ៉ាងនេះក្តី ស្ទើរតែមានការកាត់ផ្តាច់ទំនាក់ទំនងទាំងស្រុងរវាងអ្នកប្រើប្រាស់ និងអ្នកផ្តល់សេវាថែទាំសុខភាព។ ពុំមានរចនាសម្ព័ន្ធសហគមន៍ ឬយន្តការណាមួយដែលអាចអនុញ្ញាតឱ្យសហគមន៍ប្រើប្រាស់សិទ្ធិរបស់ពួកគេដើម្បីទាមទារសេវាសុខភាពឱ្យកាន់តែល្អប្រសើរ ឬយន្តការណាមួយដែលធ្វើឱ្យអ្នកប្រើប្រាស់កាន់តែមានអំណាច និងចូលរួមយ៉ាងសកម្មក្នុងការផ្តល់សេវាសម្រាប់សហគមន៍របស់ពួកគេឡើយ។ ទោះបីជាមានការទទួលស្គាល់បែបនេះក៏ដោយ វាជាការផ្ទុយស្រឡះពីព្រោះថាទាំងរដ្ឋាភិបាល និងម្ចាស់ជំនួយពុំបានផ្តល់ធនធានគ្រប់គ្រាន់សម្រាប់ការងារពង្រឹងសហគមន៍ឡើយ។

ដូចនេះអង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវឱ្យមានការដោះស្រាយបញ្ហាប្រឈមបន្ថែមទៀត ដូចតទៅ (១) ផ្តល់ធនធានបន្ថែមសម្រាប់ការពង្រឹងសហគមន៍ (២) ដោះស្រាយបញ្ហាកង្វះធនធានមនុស្ស (៣) លើកកម្ពស់គុណភាពសេវាថែទាំសុខភាព តាមរយៈការដោះស្រាយប្រភពបញ្ហា ពោលគឺការលើកកម្ពស់គុណភាពបណ្តុះបណ្តាល (៤) ដោះស្រាយលទ្ធភាពទទួលសេវាថែទាំសុខភាពប្រកបដោយសមធម៌តាមរយៈការលើកកម្ពស់សំណាញ់សុវត្ថិភាពសង្គម ឬ សេវាថែទាំសុខភាពដោយឥតបង់ថ្លៃនៅតាមកន្លែងផ្តល់សេវា (៥) ការបើកចរិកាជាតិប្រចាំឆ្នាំឱ្យបានទាន់ពេលវេលា និងពេញលេញ (៦) ប្រព័ន្ធភស្តុភារប្រកបដោយប្រសិទ្ធិភាព (៧) ដោះស្រាយបញ្ហាបុគ្គលិកពេទ្យបំពេញការងាររដ្ឋផងនិងឯកជនផង (៨) លើកកម្ពស់សុខភាពមាតា ទារក និងកុមារ (៩) ពង្រឹងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន និង (១០) រៀបចំបង្កើតក្របខ័ណ្ឌអនុវត្តន៍ល្អ ដើម្បីពង្រីកការអនុវត្តល្អទាំងនោះ។

## ៣. ផែនការអនាគត

សហគមន៍អង្គការមិនមែនរដ្ឋាភិបាល សូមសំដែងនូវការស្វាគមន៍ចំពោះឱកាសក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងការពិភាក្សាពីបញ្ហាអាទិភាព និងគោលនយោបាយអភិវឌ្ឍន៍របស់កម្ពុជា និងយុទ្ធសាស្ត្រនានាក្នុងការអនុវត្តតាមរយៈវេទិកាមួយចំនួនដូចជា ក្រុមការងារបច្ចេកទេស (TWGs) គណៈកម្មាធិការសម្របសម្រួលម្ចាស់ជំនួយ និងរដ្ឋាភិបាល (GDCC) និងកិច្ចប្រជុំលើកទីមួយរបស់វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) នេះ។

សហគមន៍អង្គការមិនមែនរដ្ឋាភិបាលសង្ឃឹមថាវេទិកាទាំងនេះនៅតែបន្តការយកចិត្តទុកដាក់ខ្ពស់ដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា។ ទន្ទឹមនឹងនេះដែរអង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់និងកោតសរសើរចំពោះបញ្ហាខាងលើនេះ។ ការពិភាក្សាជាន់ខ្ពស់នៅឯវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានៅពេលអនាគតគួរតែផ្តោតជាសំខាន់លើសូចនាករតាមដានរួមគ្នាជាអាទិភាពដែលមានចំនួនតិចតួច ហើយក្រុមការងារបច្ចេកទេសចាំបាច់ត្រូវពិនិត្យតាមដានរាល់ទិដ្ឋភាពការងាររបស់ខ្លួននៅតាមវិស័យពាក់ព័ន្ធ ជាពិសេសផ្តោតលើដំណោះស្រាយចំពោះសូចនាករតាមដានរួមគ្នាណាដែលមិនទាន់សម្រេចបាន និងបញ្ហាថ្មីៗដែលពុំបានយកចិត្តទុកដាក់កន្លងមក។ ខណៈដែលក្រុមការងារបច្ចេកទេសយល់ថាបញ្ហាសំខាន់ៗមួយចំនួនមិនទាន់បានដោះស្រាយនៅក្នុងកម្រិតបច្ចេកទេសនៅឡើយនោះ បញ្ហាទាំងនេះទាមទារឱ្យមានការយកចិត្តទុកដាក់ និងធ្វើការជជែកពិភាក្សា ជាពិសេសនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលម្ចាស់ជំនួយនិងរដ្ឋាភិបាល និងចាំបាច់បំផុតនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា។

| អង្គការមេឌីខែមគឺជាអង្គការសមាជិកភាពនៃអង្គការមិនមែន រដ្ឋាភិបាល (NGOs) ជាង ១០០ អង្គការ ដែលបំពេញការងារលើវិស័យសុខភាព នៅប្រទេសកម្ពុជា។ អង្គការមេឌីខែមដើរតួជាស្ពានរវាងអង្គការមិនមែនរដ្ឋាភិបាលដែលបំពេញការងារផ្នែក សុខភាព និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ អាណត្តិរបស់អង្គការមេឌីខែម គឺដើម្បីសម្របសម្រួល ការតស៊ូមតិ ដើម្បីកសាងសមត្ថភាពអង្គការក្នុងស្រុកមិនមែន រដ្ឋាភិបាល និងដើម្បីជាសម្លេងតំណាងឱ្យអង្គការមិនមែន រដ្ឋាភិបាល។ | **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា** គឺជាវេទិកាដែលបានរៀបចំឡើងដោយមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល (NGOs) ជាតិ និងអន្តរជាតិជាង៨០អង្គការដើម្បីស្វែងរកការពិភាក្សាចែករំលែក និងតស៊ូមតិទៅលើការព្រួយបារម្ភនៃអង្គការមិនមែនរដ្ឋាភិបាល ដែលទាក់ទងទៅនឹងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ | **គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា** (ស៊ី ស៊ី ស៊ី) គឺជាអង្គការសមាជិកភាពជាង ១០០ អង្គការដែលបានបង្កើតឡើងនៅឆ្នាំ១៩៩០សម្រាប់អង្គការមិនមែនរដ្ឋាភិបាល (NGOs) ទាំងឡាយដែលធ្វើនៅក្នុងប្រទេសកម្ពុជា។ គោលបំណងរបស់អង្គការស៊ីស៊ីស៊ីគឺធានានូវការសម្របសម្រួលផ្តល់ព័ត៌មានរវាងអង្គការមិនមែនរដ្ឋាភិបាល និងជាវេទិកាអង្គការមិនមែនរដ្ឋាភិបាល សម្របសម្រួលលើបញ្ហាសំខាន់ៗ ដែលជាក្តីកង្វល់រួម និងចូលរួមធ្វើជាតំណាងក្នុងការពិភាក្សាជាមួយម្ចាស់ជំនួយ រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលនានា និងទីភ្នាក់ងារអន្តរជាតិ។ |
|---|---|---|
| **អង្គការមេឌីខែម**<br>ផ្ទះលេខ ៤ ផ្លូវលេខ ៥២២ បឹងកក់១ ទួលគោក<br>ប្រអប់សំបុត្រប្រៃសណីយ៍: ១១៦៤ ភ្នំពេញ កម្ពុជា<br>ទូរស័ព្ទ: (៨៥៥-២៣) ៨៨០ ២៥១<br>ទូរសារ: (៨៥៥-២៣) ៨៨០២៥២<br>អ៊ីម៉ែល: info@medicam-cambodia.org<br>គេហទំព័រ: www.medicam-cambodia.org | **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា**<br>ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ ទួលទំពូង១<br>ប្រអប់សំបុត្រប្រៃសណីយ៍: ២២៩៥ ភ្នំពេញ-៣ កម្ពុជា<br>ទូរស័ព្ទ: (៨៥៥-២៣) ២១៤ ៤២៩<br>ទូរសារ: (៨៥៥-២៣) ៩៩៤ ០៦៣<br>អ៊ីម៉ែល: ngoforum@ngoforum.org.kh<br>គេហទំព័រ: www.ngoforum.org.kh | **គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា**<br>ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ ទួលទំពូង១<br>ប្រអប់សំបុត្រប្រៃសណីយ៍: ៨៨៥ ភ្នំពេញ កម្ពុជា<br>ទូរស័ព្ទ: (៨៥៥-២៣) ២១៤ ១៥២/២១៦ ០០៩<br>ទូរសារ: (៨៥៥-២៣) ២១៦ ០០៩<br>អ៊ីម៉ែល: info@ccc-cambodia.org<br>គេហទំព័រ: www.ccc-cambodia.org |


បោះពុម្ពផ្សាយដោយ:

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ ទួលទំពូង១

ប្រអប់សំបុត្រប្រៃសណីយ៍: ២២៩៥ ភ្នំពេញ-៣ កម្ពុជា

ទូរស័ព្ទ: (៨៥៥-២៣) ២១៤ ៤២៩

ទូរសារ:(៨៥៥-២៣) ៩៩៤ ០៦៣

អ៊ីម៉ែល: ngoforum@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh